ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំខែតុលា ឆ្នាំ២០១៥ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងខែតុលា ឆ្នាំ២០១៥នេះ ស្ថានភាពការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៥ បានកត់សម្គាល់ឃើញថា បរិមាណទឹកភ្លៀងបានធ្លាក់ជាមធ្យមគ្រប់តំបន់ទូទាំងប្រទេស។ មកទល់ពេលនេះ ស្ថានភាពការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៥បានបញ្ចប់ជាស្ថាពរហើយ ដោយសម្រេចបាន២.៥៥៥.១១៨ហិកតា ស្មើនឹង៩៩,៥៣ភាគរយនៃផែនការ២.៥៦៧.១៣០ហិកតា។ បើប្រៀបធៀបរយៈពេលដូចគ្នាគឺតិចជាងឆ្នាំមុនចំនួន២.៤៥៥ហិកតា។ បច្ចុប្បន្ននេះ ប្រជាកសិករបាននឹងកំពុងជំរុញការងារប្រមូលផលដំណាំរដូវវស្សាយ៉ាងសកម្ម ក្នុងនោះល្បឿននៃការប្រមូលផលស្រូវរដូវវស្សាគឺស្មើនឹង១០,៧៥%នៃផ្ទៃដីអនុវត្ត២.៥៥៥.១១៨ហិកតា ដែលទទួលបានទិន្នផលគិតជាមធ្យម៣,៤៣៤តោនក្នុងមួយហិកតា។ ក្រសួងបានណែនាំដល់អង្គភាពជំនាញក្រោមឱវាទនិងមន្ទីរកសិកម្មរាជធានី ខេត្ត យកចិត្តទុកដាក់លើការគ្រប់គ្រងនឹងប្រើប្រាស់ទឹកឲ្យមានប្រសិទ្ធភាពខ្ពស់ បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឲ្យបង្កើនការខិតខំថែទាំដំណាំស្រូវឲ្យស្របតាមបច្ចេកទេស ព្រមទាំងជំរុញការធ្វើកសិកម្មចម្រុះឲ្យអស់លទ្ធភាព ក៏ដូចជាការការពារទឹកទុកឲ្យបានគត់មត់សម្រាប់បង្កបង្កើនផលដំណាំរដូវប្រាំងនៅពេលខាងមុខនេះ។

រីឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មដែលសម្រេចបានក្នុងខែតុលា ឆ្នាំ២០១៥នេះ មានដូចខាងក្រោម៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ លទ្ធផលការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាឆ្នាំ២០១៥

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន៣.៥៥៣.៨៨៧ហិកតា ក្នុងនោះភ្ជួររាស់ដោយគោ ក្របីចំនួន៤៣៤.៣៩៧ហិកតា ស្មើនឹង១២,២២% និងគ្រឿងយន្តចំនួន៣.១១៩.៤៩០ហិកតា ស្មើនឹង៨៧,៧៨% លើសឆ្នាំមុនចំនួន៥៧៨.៧៦៦ហិកតា
- ផ្ទៃដីសាបសម្រេចបានចំនួន៧១.០៧៣ហិកតា តិចជាងឆ្នាំមុនចំនួន៤២.២៥៩ហិកតា
- ផ្ទៃដីសន្ទូងនិងពង្រោះសម្រេចបានចំនួន២.៥៥៥.១១៨ហិកតា ស្មើនឹង៩៩,៥៣% នៃផែនការ២.៥៦៧.១៣០ហិកតា តិចជាងឆ្នាំមុនចំនួន២.៤៥៥ហិកតា ក្នុងនោះស្រូវពង្រោះនិងស្រូវចម្ការ២.១២០.០៤៥ហិកតា ស្មើនឹង៨២,៩៧% ស្រូវសន្ទូងមាន៤៣៥.០៧៣ហិកតា ស្មើនឹង១៧,០៣% នៃផ្ទៃដីអនុវត្ត២.៥៥៥.១១៨ហិកតា និងស្រូវតាមប្រភេទមាន៖
  + ស្រូវស្រាលចំនួន៥៨៤.៨០៤ហិកតា (ក្នុងនោះ ស្រូវបង្កើនរដូវចំនួន១៣៣.៧២៦ហិកតា) តិចជាងឆ្នាំមុនចំនួន៧៦.៤៨១ហិកតា
  + ស្រូវកណ្តាលចំនួន១.៣០៩.៥១៥ហិកតា លើសឆ្នាំមុនចំនួន៥៨.៩២៦ហិកតា
  + ស្រូវធ្ងន់ចំនួន៥៧៤.០៩៥ហិកតា លើសឆ្នាំមុនចំនួន២៥.០២៣ហិកតា
  + ស្រូវចម្ការចំនួន៣៩.៩៤៥ហិកតា តិចជាងឆ្នាំមុនចំនួន៤.១៤៣ហិកតា
  + ស្រូវឡើងទឹកចំនួន៤៦.៧៥៩ហិកតា តិចជាងឆ្នាំមុនចំនួន៥.៧៨០ហិកតា។



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
№ 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone : (023) 726 128 / 726 129 Fax : (855) 23 - 217 320

### ១.២ ល្បឿនការងារប្រមូលផលស្រូវស្រាលដើមរដូវវស្សាឆ្នាំ២០១៥

ការងារប្រមូលផលស្រូវស្រាលដើមរដូវសម្រេចបានចំនួន២៧៤.៦៦៥ហិកតា លើផ្ទៃដីអនុវត្តសរុបចំនួន ២.៥៥៥.១១៨ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន៩៤៣.២៨៧តោន តិចជាងឆ្នាំមុន៣១.០៣៧តោន និងទិន្នផលជាមធ្យមចំនួន៣,៤៣៤តោនក្នុងមួយហិកតា លើសឆ្នាំមុន៨២គីឡូក្រាមក្នុងមួយហិកតា។

### ១.៣ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម

- ផ្ទៃដីដំណាំរួមផ្សំសម្រេចបានចំនួន៧៤៤.០១៦ហិកតា ស្មើនឹង១៣២,៩៦% នៃផែនការ៥៥៩.៥៥៩ហិកតា លើសឆ្នាំមុនចំនួន៥៩.៩៥៨ហិកតា
- ផ្ទៃដីដំណាំឧស្សាហកម្មសម្រេចបានចំនួន១២០.២៧៥ហិកតា ស្មើនឹង៩២,៧០%នៃផែនការ១២៩.៧៤២ហិកតា តិចជាងឆ្នាំមុនចំនួន៨.៤៣៣ហិកតា។

### ១.៤ ល្បឿនការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៥-២០១៦

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន១១៥.៧៧៧ហិកតា លើសឆ្នាំមុនចំនួន៩៥.០៣៦ហិកតា ក្នុងនោះភ្ជួររាស់ដោយគោ ក្របីចំនួន៣.៨៥៤ហិកតា និងគ្រឿងយន្តចំនួន១១១.៩២៣ហិកតា
- ផ្ទៃដីសាបសម្រេចបានចំនួន២៣៧ហិកតា តិចជាងឆ្នាំមុនចំនួន៣៥៩ហិកតា
- ផ្ទៃដីសន្ទូងនិងពង្រោះសម្រេចបានចំនួន៥៥.២៦៤ហិកតា ស្មើនឹង១៣,១៥% នៃផែនការ៤២០.៣៥០ហិកតា លើសឆ្នាំមុនចំនួន៤.៣៨៥ហិកតា។

### ១.៥ ស្ថានភាពប៉ះពាល់និងខូចខាតដោយគ្រោះធម្មជាតិ

គ្រោះខ្វះទឹកប៉ះពាល់លើផ្ទៃដីសរុបចំនួន២៣៤.៦៩៥ហិកតា ក្នុងនោះមានសំណាបសរុបចំនួន២.៥៩៦ហិកតា និងសន្ទូង-ពង្រោះសរុបចំនួន២៣២.០៩៩ហិកតា។ ក្នុងស្ថានភាពបែបនេះ ប្រជាកសិករបានខិតខំស្តារឡើងវិញលើផ្ទៃដីដែលបានខូចខាត។ ជាក់ស្តែងសំណាបខូចខាតចំនួន៦៤ហិកតា សន្ទូង-ពង្រោះខូចខាតចំនួន១៤.០៤៤ហិកតា។ ទិន្នន័យនេះមិនមានការប្រែប្រួលទៀតឡើយ ព្រោះការងារបង្កបង្កើនផលស្រូវរដូវវស្សាត្រូវបានបញ្ចប់ជាស្ថាពរហើយ។

### ១.៦ ការនាំចេញអង្ករ

គួរកត់សម្គាល់ថា ការនាំចេញអង្ករកម្ពុជាក្នុងរយៈពេល១០ខែដើមឆ្នាំ២០១៥នេះ មានបរិមាណចំនួន៤០៨.១៦៩ តោន ដែលមានការកើនឡើងចំនួន១០៣.៣៨១តោន(+៣៣,៩%) លើសបរិមាណនាំចេញក្នុងរយៈពេល១០ខែដើមឆ្នាំ ២០១៤ (ដែលមានតែ៣០៤.៧៨៨តោន)។ ដោយឡែកបរិមាណអង្ករនាំចេញក្នុងខែតុលា ឆ្នាំ២០១៥នេះ មានតែ ៣៩.០៦៤តោន ដែលមានការកើនឡើងចំនួន៣.៦៤៦តោន(+១២,១%)លើសបរិមាណនាំចេញក្នុងខែតុលា ដើមឆ្នាំ ២០១៤ ដែលមាន៣៥.៤១៨តោន និងនាំចេញទៅកាន់ទិសដៅចំនួន៥៨ប្រទេស។

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីចម្ការកៅស៊ូសរុប (ហ.ត) | ផលិតផលអនុវត្តបានដល់ខែនេះ (តោន) | បញ្ចេញលក់ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៥០៨,00 | ៧៥៧,00 | ៥៣៧,៥២ | ៣៤៩,00 |
| សរុប I | | ៥០៨,00 | ៧៥៧,00 | ៥៣៧,៥២ | ៣៤៩,00 |
| II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អិនវេសមេន គ្រុប | ១១.៦១៨,00 | ១៦.០២៨,00 | ១៥.៥៥១,០៣ | ១២.៦៧៧,៤៤ |
| ២ | ក្រុមហ៊ុន ស៊ីហ្វ៉ាប់ប៊ើលីមីធីត (រតនគីរី) | ៧៩,00 | ២.១៤៣,00 | ២៦៩,៥៥ | - |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ១.២៤២,00 | ២.២៩៩,00 | ៩១៩,២៤ | ៧០១,៦០ |
| ៤ | ក្រុមហ៊ុន ឡុង ស្រេង | ២.៦៤៦,00 | ៥.៧១១,00 | ៥.៤២៨,៥៧ | ៤.៦១៨,១៨ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៦៩,00 | ៨.៦១៥,00 | ២.៩៣៩,៩៩ | ២.០៥៣,២០ |

| | | | | | |
|---|---|---|---|---|---|
| ៦ | ក្រុមហ៊ុន ស៊ីហ្វឺសេសស៍ (ស្នួល) | ១.៧៤៥,០០ | ៤.៣៦៥,០០ | ១.៨០២,២៧ | ១.៤១០,០០ |
| ៧ | ក្រុមហ៊ុនអានម៉ាឌីគ្រុប (ពាមជាំង,តាសែហោក) | ២.០៣០,០០ | ៤.១៤៣,០០ | ១.០៣១,៥៨ | ៦៦៥,២០ |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ៣.១១២,០០ | ៥.៩២៥,០០ | ១.៣២៦,៥៤ | ១.០៣៤,៨០ |
| ៩ | ក្រុមហ៊ុនគ្រែក (ខេមបូឌា) ខូអិលធីឌី | ៣.២៥៦,០០ | ៥.៧៣១,០០ | ៤.២៨៣,១២ | ៣.៣១៩,៤០ |
| សរុប II | | ២៨.៩៩៧,០០ | ៥៤.៩៦០,០០ | ៣៣.៥៥១,៨៩ | ២៦.៤៧៩,៨២ |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចម្ការកៅស៊ូគ្រួសារ | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៦.៤១៥,០០ | ១៦១.៦៧៧,០០ | ៣.៧៤៧,០០ | ៣.៧៤៧,០០ |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៧៣.៣៩៦,០០ | ១៤០.៣៤៦,០០ | ៥៨.៧៩៨,០០ | ៥៧.៥៩៨,០០ |
| សរុប III | | ៧៩.៨១១,០០ | ៣០២.០២៣,០០ | ៦២.៥៤៥,០០ | ៦១.៣៤៥,០០ |
| សរុប I+II+III | | ១០៩.៣១៦,០០ | ៣៥៧.៧៤០,០០ | ៩៦.៦៣៤,៤១ | ៨៨.១៧៣,៨២ |

• គួរកត់សម្គាល់ថា ក្នុងខែតុលា ឆ្នាំ២០១៥នេះ តម្លៃកៅស៊ូជាមធ្យមគឺ១.១៤៦ ដុល្លារក្នុងមួយតោន

• ក្រសួងបានរៀបចំសន្និសីទ កិច្ចប្រជុំ និងសន្និបាតប្រចាំឆ្នាំ២០១៥ របស់សមាគមនៃបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC) នៅខេត្តសៀមរាប ចាប់ពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ ដល់ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៥ ដែលមានសមាជិកចូលរួមប្រមាណជាង៣០០នាក់ ក្នុងនោះភ្ញៀវអន្តរជាតិមកពី១៣ប្រទេស។

### ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- ចូលរួមសិក្ខាសាលាវិទ្យាសាស្ត្រលើកទី៦នៃវេទិកាស្រាវជ្រាវកៅស៊ូក្នុងភាពជាដៃគូ និងធ្វើបទបង្ហាញស្តីពីកៅស៊ូនៅកម្ពុជា នៅខេត្តខុនកេន ប្រទេសថៃ
- ចូលរួមសន្និសីទកៅស៊ូរបស់សមាគមប្រទេសផលិតកៅស៊ូធម្មជាតិលើកទី៨ ប្រចាំឆ្នាំ២០១៥ នៅខេត្តសៀមរាប
- ចុះបេសកកម្មតាមបណ្តាខេត្តដែលមានចម្ការកៅស៊ូ ដើម្បីចូលរួមសហការរាល់ការងារដែលពាក់ព័ន្ធនឹងបច្ចេកទេសកៅស៊ូ និងតាមដានការពិសោធន៍និងស្រង់ទិន្នន័យពិសោធន៍តាមការិយាល័យនីមួយៗ
- វិភាគលទ្ធផលចូលរួមធ្វើតេស្តអន្តរមន្ទីរពិសោធន៍អន្តរជាតិលើកទី១១៣ ជាមួយ IRA (International Rubber Association) ដើម្បីការទទួលស្គាល់ជាមន្ទីរពិសោធន៍យោងក្នុងតំបន់សម្រាប់កិច្ចសន្យាកៅស៊ូ TSR (Technically Specified Rubber)
- ដាក់ជីបំប៉នកូនកៅស៊ូលើកទី២គ្រប់ចម្ការពិសោធន៍ និងបាញ់ថ្នាំការពារនិងព្យាបាលជំងឺផ្កាកូលាបលើកទី២
- ចុះពិនិត្យនិងវាយតម្លៃច្បារពូជកៅស៊ូនៅខេត្តសៀមរាប ដើម្បីចេញវិញ្ញាបនបត្រច្បារពូជកៅស៊ូជូនកសិករ
- វិភាគ DRC តាមមេត្រូឡាក់ តាមការដុតរក TSC និងការវិភាគតាមមន្ទីរពិសោធន៍សម្រាប់ចម្ការពិសោធន៍នីមួយៗ
- ទទួលក្លូនកៅស៊ូពីប្រទេសឥណ្ឌាបានចំនួន៥ក្លូន: RRII430, RRII429, RRII422, RRII417, RRII414 សរុបមានប្រវែង២៥ម៉ែត្រ ដើម្បីដាំសាកល្បងនិងធ្វើការស្រាវជ្រាវជាបន្ត
- បណ្តុះបណ្តាលនិស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មកំពង់ចាម និងដឹកនាំនិស្សិតសរសេរសារណាបញ្ចប់ការសិក្សាមកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មកំពង់ចាម និងសាកលវិទ្យាល័យស្វាយរៀង។

## ៣ ផ្នែកផលិតកម្មនិងបសុព្យាបាល

**៣.១ ការងារផលិតកម្ម៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ការចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត ការរៀបចំឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តាខេត្តនិងរាជធានីរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖

• ការងារកែលម្អពូជ៖ ការកែលម្អពូជកំពុងតែឈានឆ្ពោះទៅមុខជាបណ្តើរ ព្រោះប្រជាកសិករភាគច្រើនកាន់តែមានការយល់ដឹងពីការជ្រើសរើសពូជសត្វដែលផ្តល់ទិន្នផលខ្ពស់ ការលូតលាស់ឆាប់រហ័ស ធន់នឹងជំងឺ និងផ្តល់ប្រាក់ចំណូលគ្រួសារខ្ពស់។

• **ការងារឡជីវឧស្ម័ន៖** ដោយមានការអភិវឌ្ឍផ្នែកចិញ្ចឹមសត្វ ការគ្រប់គ្រងកាកសំណល់ពីសត្វក៏ត្រូវបានយកចិត្តទុកដាក់ខ្ពស់តាមរយៈការអប់រំ ណែនាំ ផ្សព្វផ្សាយការអនុវត្តល្អប្រសើរការចិញ្ចឹមសត្វ ការសាងសង់ឡជីវឧស្ម័ននៅកសិដ្ឋានចិញ្ចឹមសត្វ និងនៅតាមគ្រួសារកសិករចិញ្ចឹមសត្វ។ ការសាងសង់ឡជីវឧស្ម័នថ្នាក់ជាតិបាននឹងកំពុងអនុវត្តន៍យ៉ាងសកម្មដែលមកទល់ពេលនេះ ខេត្តដែលស្ថិតក្រោមការអនុវត្តកម្មវិធីឡជីវឧស្ម័នមាន៖ ខេត្តកំពង់ចាម ស្វាយរៀង ព្រៃវែង តាកែវ កំពង់ស្ពឺ កណ្តាល កំពង់ឆ្នាំង កំពត សៀមរាប កំពង់ធំ ត្បូងឃ្មុំ និងពោធិ៍សាត់សម្រេចបាន១៦៩ឡ និងឡគម្រោងសាធារណរដ្ឋប្រជាមានិតចិនសម្រេចបាន១២០ឡ(គិតត្រឹមថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៤) សរុបរួមៈ ២៨៩ឡ។

• **ចំណីសត្វ៖** បច្ចុប្បន្ននេះមានការវិនិយោគលើការបង្កើតរោងចក្រចំណីសត្វសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក ហើយបានកាត់បន្ថយការនាំចូលចំណីសត្វយ៉ាងច្រើន។ ដោយឡែកប្រជាកសិករមានការចូលរួមយ៉ាងសកម្មក្នុងការផលិត និងមានការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វនិងចំណីផ្សំស្រេចយ៉ាងផុសផុល។

• **ការងារដំណាំចំណីសត្វ៖** តាមបណ្តាខេត្តមួយចំនួនបានធ្វើសួនដំណាំចំណីសត្វ ការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ព្រមទាំងផ្តល់ពូជស្មៅដល់កសិករនិងភ្នាក់ងារសុខភាពសត្វភូមិ ក្រោមកិច្ចសហការជាមួយគម្រោងអន្តរជាតិដូចជា ACIAR និងCIAT ជាដើម។

### ៣.២ ការងារបសុព្យាបាល

• លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖

ខេត្ត-រាជធានីចំនួន១១ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគនៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វចំនួន៤.៩៧៦លើក។ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យនិងបង្ក្រាប ដោយបានកប់និងកម្ទេចចោលផលិតផលសាច់ខូចគុណភាពតាមវិធានបសុពេទ្យចំនួន៩៥,៦គីឡូក្រាម រឹបអូសផលិតផលសត្វខូចគុណភាព(ថ្លើមជ្រូក,ក្រលៀនជ្រូក,សួតជ្រូក,ផាលគោ-ក្របី និងថ្លើមគោ-ក្របី)សរុបចំនួន៤៣គូ ផុតបំផ្លាញចោលជ្រូកមានជំងឺចំនួន១១ក្បាល និងបង្ក្រាបបទល្មើសអាជីវកម្មខុសច្បាប់ចំនួន០១ករណី។

• **ការងារសុខភាពសាធារណៈ៖** ចុះត្រួតពិនិត្យទីតាំងស្នើសុំបង្កើតនិងបន្តសុពលភាពសត្តឃាតដ្ឋានប្រភេទ «ក» និង«ខ»តាមបណ្តារាជធានី-ខេត្ត និងចុះត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋានឱ្យស្របតាមលក្ខណៈបច្ចេកទេស។

• **ការងារនីតិកម្មនិងវិវាទ៖** សេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ បានបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីរួច និងត្រៀមលក្ខណៈដើម្បីប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។ បន្តរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ សេចក្តីព្រាងប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ និងសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីកិច្ចសម្របសម្រួលក្នុងការបង្កើតនិងការគ្រប់គ្រងសត្តឃាតដ្ឋាន ព្រមទាំងរៀបចំផែនការយុទ្ធសាស្ត្រវិស័យសុខភាពសត្វនិងផលិតកម្មសត្វរយៈពេល១០ឆ្នាំ (២០១៥-២០២៤)។

• បានចេញប្រកាសស្តីពីការរំសាយតំបន់ជំងឺជ្រូកត្រចៀកខៀវចំនួន១០កន្លែង គឺខេត្តកំពង់ចាមចំនួន២កន្លែង ខេត្តស្វាយរៀងចំនួន២កន្លែង ខេត្តសៀមរាបចំនួន៤កន្លែង និងខេត្តព្រៃវែងចំនួន២កន្លែង។

### ៣.៣ ការងារស្រាវជ្រាវ៖

• **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោ-ក្របីភ្នំតាម៉ៅមានគោសរុបចំនួន ១៥៧ក្បាល ក្នុងនោះគោបា៣ក្បាល គោប្រាម៉ាន់កាត់៣៣ក្បាល គោជំទង់៣៤ក្បាល គោបៅដោះ៤៥ក្បាល គោកំផែងសែន៤២ក្បាល គោកើតថ្មី៣ក្បាល និងគោងាប់ចំនួន១ក្បាល។ ដោយឡែកនៅស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនមានជ្រូកសរុប២៩៩ក្បាល ក្នុងនោះជ្រូកបាចំនួន៦ក្បាល ជ្រូកមេ៧៩ក្បាល កូនជ្រូក៨៩ក្បាល កូនជ្រូកលក់១០០ក្បាល កូនជ្រូកងាប់ចំនួន១៨ក្បាល និងកូនជ្រូកទុកបម្រុងចំនួន៧ក្បាល។ ការបង្កាត់ពូជតាមបែបសិប្បនិម្មិតនិងធម្មជាតិប្រព្រឹត្តទៅជាប្រក្រតី និងបានផ្សព្វផ្សាយបច្ចេកទេសបន្តទៅដល់កសិករ។

• **ការងារស្រាវជ្រាវបសុព្យាបាល៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាន និងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺនិងងាប់ ដើម្បីវិភាគរកប្រភេទមេរោគបង្កជំងឺជាពិសេសមេរោគជំងឺផ្តាសាយបក្សី មេរោគជ្រូកត្រចៀកខៀវជាដើម។ ជាក់ស្តែងក្នុងខែតុលា ឆ្នាំ២០១៥នេះ វិទ្យាស្ថានស្រាវជ្រាវបសុព្យាបាលបានពិនិត្យវត្ថុវិភាគសរុបចំនួន៨៣ករណី។

៣.៤ ការងារផ្សព្វផ្សាយបច្ចេកទេស៖ ចងក្រងឯកសារការងារផលិតកម្មនិងបសុព្យាបាលសម្រាប់ចុះក្នុងទស្សនាវដ្ដី រៀបចំកម្មវិធីផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល ជាពិសេសផ្សព្វផ្សាយដល់ប្រជាជនឱ្យយល់ដឹងពីជំងឺផ្ដាសាយបក្សី ជំងឺជ្រូកត្រចៀកខៀវ និងជំងឺផ្សេងៗទៀតដែលអាចកើតឡើងជាយថាហេតុ។

## ៤ ផ្នែកព្រៃឈើ

### ៤.១ ការងារព្រៃឈើ

- ចូលរួមប្រជុំអន្តរនាយកដ្ឋាន ដើម្បីពិភាក្សាលើសេចក្ដីព្រាងប្រកាសស្ដីពីការបង្កើតនិងគ្រប់គ្រងតំបន់ព្រៃសហគមន៍ ស្ថិតនៅក្នុងខេត្តព្រះវិហារ ចំនួន២សហគមន៍ព្រៃឈើ គ្របដណ្ដប់លើផ្ទៃដីទំហំ១.៨០២ហិកតា

- ចុះផ្សព្វផ្សាយលិខិតបទដ្ឋានច្បាប់សហគមន៍ព្រៃឈើដល់សហគមន៍ព្រៃឈើចំនួន២សហគមន៍ព្រៃឈើ នៅក្នុងខេត្តមណ្ឌលគិរី មានអ្នកចូលរួមសរុបចំនួន៦៨នាក់(ស្ត្រីចំនួន១៧នាក់) ដែលជាគណៈកម្មការសហគមន៍ព្រៃឈើ សមាជិកសហគមន៍ព្រៃឈើ និងអាជ្ញាធរដែនដី

- រៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពី"ការពង្រឹងប្រព័ន្ធសិទ្ធកាន់កាប់ដីព្រៃឈើនិងអភិបាលកិច្ចព្រៃឈើ" ដោយសហការជាមួយអង្គការ FAO និង NTFP-EP ដែលមានការចូលរួមពីរដ្ឋបាលព្រៃឈើថ្នាក់កណ្ដាល នាយកដ្ឋាន នាយខណ្ឌរដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន ក្រសួងមហាផ្ទៃ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអង្គការដៃគូសរុបប្រមាណ២៨នាក់ ក្នុងនោះស្ត្រីចំនួន៥នាក់។

### ៤.២ ការងារអភិរក្សសត្វព្រៃ

- កំពុងរៀបចំអនុក្រឹត្យស្ដីពីការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃព្រះរការ ដែលមានទំហំ៩២.១៣២ហិកតា ស្ថិតក្នុងខេត្តព្រះវិហារ

- កំពុងបន្តពិភាក្សាការបង្កើតតំបន់ព្រៃការពារព្រៃឡង់ ព្រៃជួរភ្នំក្រវាញភាគខាងត្បូង និងវ៉ើនសៃ ដែលមានផ្ទៃដីសរុបប្រហែល១.០២៤.៣០១ហិកតា

- មានភ្ញៀវទេសចរណ៍បរទេសចំនួន៨នាក់ មកទស្សនាតំបន់អភិរក្សជីវចម្រុះវ៉ើនសៃ អាងត្រពាំងថ្ម និងសីមា

- កំពុងរៀបចំផែនការគ្រប់គ្រងតំបន់ព្រៃការពារមណ្ឌលគិរី និងតំបន់អភិរក្សសត្វក្រៀលអាងត្រពាំងថ្ម

- ធ្វើការអង្កេតកត់ត្រាសត្វស្លាបប្រចាំខែនៅតាមតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន៤កន្លែង (អាងត្រពាំងថ្ម បឹងព្រែកល្ពៅ អន្លង់ព្រីង និងកំពង់ធំ-សៀមរាប)ដែលមានសត្វស្លាបចំនួន១៨៩ប្រភេទ (ប្រហែល៤៥.៩៩៥ក្បាល)

- ចុះប្រមូលសំណាកសត្វប្រចៀវរស់បានចំនួន១៨៧ក្បាល សត្វជ្រូងចំនួន៣៧ក្បាល ដើម្បីធ្វើការពិនិត្យទៅលើឈាម លាមក ទឹកមាត់ ទឹកនោម និងវាស់ប្រវែងស្លាបដើម្បីវិភាគរកមេរោគ និងការបន្តពូជ

- ចុះប្រមូលទិន្នន័យសំណាកជំងឺសត្វកណ្ដុរព្រៃនៅខេត្តកំពង់ធំ សរុបចំនួន៨៩៧សំណាក ដែលប្រមូលបានពីសត្វកណ្ដុរព្រៃចំនួន១១៧ក្បាល

- ផ្ដល់ចំណីដល់ត្មាតនៅខេត្តស្ទឹងត្រែង ខេត្តក្រចេះ និងតំបន់ព្រៃការពារខេត្តព្រះវិហារ ដោយរាប់ឃើញត្មាតសរុបប្រមាណ៤៧ក្បាល។ ការផ្ដល់ចំណីដល់ត្មាតគឺដើម្បីធានាការរស់រានរបស់សត្វត្មាត និងធ្វើការអង្កេតតាមដាន

- ចុះណែនាំអំពីវិធានការទប់ស្កាត់ការបំផ្លាញដំណាំរបស់ប្រជាពលរដ្ឋដោយសារសត្វដំរីព្រៃ និងបានចែកកណ្ដឹងចំនួន៦០០កណ្ដឹង ពិលចំនួន១៩ និងខ្សែសម្រាប់ចងរបងចំនួន១.២០០ម៉ែត្រ ជូនប្រជាជនដើម្បីទុកបង្អើល។

### ៤.៣ កសិដ្ឋានចិញ្ចឹម ការបង្កាត់ពូជស្វាក្ដាម និងការសង្គ្រោះសត្វព្រៃ

- សម្រាប់ខែតុលា ឆ្នាំ២០១៥នេះ ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹមនិងថែរក្សាគឺ៖ សង្គ្រោះសត្វព្រៃថ្មីគ្រប់ប្រភេទចំនួន១០៣ក្បាល សត្វកើតថ្មីចំនួន៩ក្បាល ដោះលែងទៅព្រៃធម្មជាតិវិញចំនួន១៦៩ក្បាល សត្វស្លាប់ចំនួន៣៨ក្បាល ព្យាបាលសត្វចំនួន៣៤ក្បាល យកសំណាកទៅពិសោធន៍ចំនួន៩ក្បាល ធ្វើឲ្យសន្លប់ចំនួន៥ក្បាល ទម្លាក់សត្វល្អិតចំនួន៥២ក្បាល វះកាត់សាកសពសត្វចំនួន១១ក្បាល ដាក់លេខកូដចំនួន៣ក្បាល ជួលជុលផ្លូវចំនួន៣៧.៧២០ម$^{២}$ សាងសង់បង្គោលភ្លើងចំនួន១០ដើម កាប់ឆ្ការអនាម័យព្រៃចំនួន១.៨០០ម$^{២}$ ដាំកូនឈើចំនួន៤៤ដើម បណ្ដុះផ្កាលម្អចំនួន១.០៣៨ដើម និងអប់រំផ្សព្វផ្សាយសិស្សនិស្សិតចំនួន៧៤៣នាក់

- ក្រុមហ៊ុនចំនួន៦ គ្រប់គ្រងកសិដ្ឋានចំនួន៧ កំពុងចិញ្ចឹមស្វាក្ដាមចំនួន៥៤.២៣៨ក្បាល។

### ៤.៤ ការងារដាំដើមឈើ

- ការដាំឈើជាចម្ការថ្មីនៅតាមបណ្តាស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើរបស់រដ្ឋបាលព្រៃឈើចំនួន៣ (ស្ថានីយយុនរាម ក្បាលឆាយបានបញ្ចប់ការដាំដុះ និងស្ថានីយអូរបឹងរូងបានបញ្ចប់ការឈូសឆាយនិងបន្តការដាំដុះ) ដោយ ដាំកូនគ្រញូងនិងធ្នង់បានចំនួន៣៥ហិកតា

- ដាំជួសកូនឈើក្នុងឡូត៍ពិសោធន៍បានចំនួន៣០០ដើម និងកាប់ល្បាស់សម្អាតកូនឈើក្នុងឡូត៍ពិសោធន៍បានចំនួន១.៥០០ដើម ព្រមទាំងថែទាំស្រោចទឹកកូនឈើដែលនៅសល់ក្នុងថ្នាលបណ្តុះនិងយាមការពារកូនឈើក្នុងឡូត៍ដែលបានដាំរួចជាប្រចាំ

- ការដាំឈើដៃគូជាមួយក្រុមហ៊ុន ស៊ីងបាយអូចេក ខេមបូឌា ឌូអិលធីឌី បានឈូសឆាយសម្អាតដីចំនួន១៨០ហិកតា ដាំដុះកូនឈើលើផ្ទៃដីទំហំ២០០ហិកតា និងផលិតពូជកូនឈើបានចំនួន៦០០.០០០ដើម

- ការងារពិសោធន៍(Tissue Culture)បំបែក ផ្លាស់ប្តូរសារធាតុចិញ្ចឹមថ្មីអ័រគីដេដែលមានស្រាប់បានចំនួន១.០០០ដើម

- តាមដានការលូតលាស់មែកគ្រញូង ធ្នង់ អាកាស្យា និងគ្រញូងដែលបានពីស្លឹក ឫស និងដើម ជារៀងរាល់ថ្ងៃ

- ការងារថ្នាលបណ្តុះដើមឈើ៖ បានបណ្តុះគ្រញូងចំនួន១.០០០កូន ត្រយឹងចំនួន៧០០កូន ក្រឡាញ់ចំនួន៥០០កូន ស្បែរៀងចំនួន២០០០កូន និងបន្លែចំនួន៧រង

- ចុះប្រមូលទិន្នន័យស្រាវជ្រាវប្រចាំខែក្នុងខេត្តកំពង់ធំចំនួន១លើក និងខេត្តក្រចេះចំនួន១លើក។ បញ្ជូនទិន្នន័យដែលប្រមូលបានទៅធ្វើការវិភាគនៅវិទ្យាស្ថានស្រាវជ្រាវវិស័យព្រៃឈើ និងផលិតផលព្រៃឈើប្រទេសជប៉ុន។

### ៤.៥ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញផលិតផលឈើកែច្នៃជូនក្រុមហ៊ុនចំនួន២ ដែលមានបរិមាណឈើកែច្នៃចំនួន៣.៧២៤ម៣

- ពិនិត្យឯកសារស្នើសុំពន្យារអាជ្ញាប័ណ្ណនាំចេញ និងបានផ្តល់ពន្យារទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញចំណិតឈើអាកាស្យា និងប្រេងខ្យល់ចំនួន១ក្រុមហ៊ុន ដែលមានបរិមាណចំនួន៣.០០០តោន

- បាននឹងកំពុងរៀបចំសំណើសុំគោលការណ៍នាំចេញឈើអាកាស្យាកែច្នៃចំនួន១ក្រុមហ៊ុន ដែលមានបរិមាណឈើអាកាស្យាកែច្នៃចំនួន២០.២១៧,៧៨៦ស្ទែរ

- ពិនិត្យឯកសារស្នើសុំបង្កើតរោងសិប្បកម្មកែច្នៃឈើ និងគ្រឿងសង្ហារិមជូនក្រុមហ៊ុនចំនួន១ និងស្នើសុំពន្យាររោងម៉ាស៊ីន និងរោងសិប្បកម្មកែច្នៃឈើផលិតគ្រឿងសង្ហារិមជូនក្រុមហ៊ុនចំនួន៣

- ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចេញជូនក្រុមហ៊ុនចំនួន១ ស្មើនឹង១សន្លឹក ដែលមានបរិមាណឈើចំនួន២៦ម៣

- ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចូលជូនក្រុមហ៊ុនចំនួន១ ស្មើនឹង២សន្លឹក ដែលមានបរិមាណឈើឡាំងជ្រុងចំនួន៦៦ម៣ ។

### ៤.៦ ការងារចំណូលព្រៃឈើ

- សម្រាប់ខែតុលា ឆ្នាំ២០១៥នេះ ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើសរុបចំនួន៥៥៨.៦៥៦.១៩៨រៀល និងចំណូលពីសេវាសាធារណៈចំនួន៤២៦.១០៤.៥៨០រៀល និង៣០.១០១,៥៣ដុល្លារ។

### ៤.៧ ការងារនីតិកម្មនិងវិវាទ

- សម្រាប់ខែតុលា ឆ្នាំ២០១៥នេះ មានសំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃនៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានសរុបចំនួន១៣១ករណី ដោយបញ្ជូនទៅតុលាការចំនួន៧០ករណី និងពិន័យអន្តរការណ៍ចំនួន៦១ករណី

- ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន១៦ម៣ ឈើអារចំនួន២២៥ម៣ ឈើប្រាក់គ្រញូងចំនួន៣ម៣ សត្វព្រៃចម្រុះគ្រប់ប្រភេទចំនួន៧៥គ.ក្រ អនុផលព្រៃឈើ សម្ភារផ្សេងៗមួយចំនួនទៀត និងដីព្រៃឈើដែលកាប់រានចំនួន៥០ហិកតា ព្រមទាំងបានបញ្ជូនសំណុំរឿងទៅតុលាការ និងដកហូតរណារយន្តចំនួន៧គ្រឿង

- បន្តដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ (Case Tracking System-CTS) ដើម្បីរៀបចំឱ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប

- ចុះពង្រឹងការអនុវត្តក្នុងការតាមដានស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ ដេប៉ូឈើ និងរោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើនៅខេត្តកំពង់ធំ ព្រះវិហារ សៀមរាប និងខេត្តឧត្តរមានជ័យ

- ស្រង់ព័ត៌មានពាក់ព័ន្ធវិស័យព្រៃឈើដែលបានចុះផ្សាយក្នុងសារព័ត៌មាននានាសរុបចំនួន៧៣ករណី ដែលការចុះផ្សាយនេះឆ្លុះបញ្ចាំងពីចំណុចវិជ្ជមានផង និងអវិជ្ជមានផងដែរ និងបានផ្ញើជូនខណ្ឌរដ្ឋបាលព្រៃឈើធ្វើការបំភ្លឺមានចំនួន១៧ករណី ហើយបណ្តាខណ្ឌរដ្ឋបាលព្រៃឈើបានធ្វើការបំភ្លឺមកវិញមានចំនួន២ករណី។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រីធ្វើអាជីវកម្ម ក្នុងខែតុលា អនុវត្តបានចំនួន១២៥តោន ស្មើ១,២៥% នៃផែនការ១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន១.៨៧៥តោន

- នេសាទគ្រួសារក្នុងដែននេសាទ ក្នុងខែតុលា អនុវត្តបានចំនួន៣៣.២៥០តោន សរុបរយៈពេល១០ខែបានចំនួន២៥៣.៦០០តោន ស្មើ៧២,៤៦% នៃផែនការ៣៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួន៨.៦០០តោន

- នេសាទគ្រួសារតាមវាលស្រែ ក្នុងខែតុលា អនុវត្តបានចំនួន១៧.៩០៣តោន សរុបរយៈពេល១០ខែបានចំនួន១០៥.២៥៨តោន ស្មើ៧០,១៧% នៃផែនការ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួន៥.២៥៨តោន។

#### ៥.១.២ នេសាទសមុទ្រ

ក្នុងខែតុលា អនុវត្តបានចំនួន១១.៥០០តោន សរុបរយៈពេល១០ខែចំនួន៨៩.៥០០តោន ស្មើ៨១,៣៦% នៃផែនការ១១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន៥០០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គា ក្នុងខែតុលា អនុវត្តបានចំនួន១២.០០០តោន សរុបរយៈពេល១០ខែបានចំនួន១២៤.១០០តោន ស្មើ៨៦,១៨%នៃផែនការ១៤៤.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួន៤២.១០០តោន

- ការចិញ្ចឹមក្រពើ ក្នុងខែតុលា អនុវត្តបានចំនួន២០.០០០ក្បាល សរុបរយៈពេល១០ខែបានចំនួន២០៥.៥០០ក្បាល ស្មើ៨២,២០%នៃផែនការ២៥០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន២៤.៥០០ក្បាល

- ការភ្ញាស់កូនត្រីពូជ ក្នុងខែតុលា អនុវត្តបានចំនួនប្រមាណ១៥.០០០.០០០កូន សរុបរយៈពេល១០ខែ បានចំនួនប្រមាណ១៦០.០០០.០០០កូន ស្មើ៨៨,៨៩% នៃផែនការ១៨០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួនប្រមាណ៥.០០០.០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទ២០១៤-២០១៥ ក្នុងខែតុលា អនុវត្តបានចំនួន១.៥០០តោន សរុបរយៈពេល១០ខែបានចំនួន៤៦.៥០០តោន ស្មើ៥៦,៧១% នៃផែនការ៨២.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន១១.៥០០តោន

- ផលនេសាទសមុទ្រក្នុងឆ្នាំ២០១៥ ក្នុងខែតុលា អនុវត្តបានចំនួន៥០០តោន សរុបរយៈពេល១០ខែបានចំនួន៨.៣០០តោន ស្មើ១០៣,៧៥% នៃផែនការ៨.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួន១.៣០០តោន

- ការផលិតទឹកត្រីក្នុងខែតុលា អនុវត្តបានចំនួន២.០០០.០០០លីត្រ សរុបរយៈពេល១០ខែបានចំនួន៥២.០០០.០០០លីត្រ ស្មើ១០៤% នៃផែនការ៥០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន៦.០០០.០០០លីត្រ។

### ៥.៤ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់ ក្នុងខែតុលា អនុវត្តបានចំនួន៧០០តោន សរុបរយៈពេល១០ខែបានចំនួន៧.៨០០តោន ស្មើ៥២% នៃផែនការ១៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន២.២០០តោន

- ផលនេសាទកែច្នៃ ក្នុងខែតុលា អនុវត្តបានចំនួន៥០០តោន សរុបរយៈពេល១០ខែបានចំនួន៤.២០០តោន ស្មើ៨៤% នៃផែនការ៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន១.៣០០តោន។

### ៥.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស

- នៅក្នុងខែតុលា ឆ្នាំ២០១៥នេះ សំណុំរឿងបទល្មើសជលផលមានចំនួន៤៧៩ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន៤៧២ករណី និងបទល្មើសសមុទ្រចំនួន៧ករណី

- បានផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានក្រោមច្បាប់ពាក់ព័ន្ធចំនួន១០២វគ្គ ដោយមានអ្នកចូលរួមចំនួន៨.៩២១នាក់ ក្នុងនោះស្ត្រីចំនួន៣.៣២៥នាក់

- ចុះរុះរើនិងបំផ្លាញចោលវត្ថុតាងបទល្មើសជលផលរួមមាន៖ របាំងស្បៃមុងនិងសាច់អួនប្រវែង៣៧៥.២៦៣ម៉ែត្រ លូស្បៃមុងនិងសាច់អួនចំនួន៧.២០៩មាត់ បង្គោល/ចម្រឹងចំនួន១០៨.១៥៦ដើម ឧបករណ៍ឆក់ត្រីចំនួន២៣គ្រឿង របាំងព្រួលប្រវែង១.០៩២ម៉ែត្រ លបកែច្នៃ(កន្ទុយកណ្ដុរ/ពោះវៀនជ្រូក)ចំនួន៨០គ្រឿង លែងត្រីចម្រុះចូលក្នុងបឹងធម្មជាតិចំនួន៤៦.៧៧៦គ.ក្រ និងកូនត្រីឆ្តោចំនួន១៥៩.៨០០ក្បាល

- ថ្នាក់ដឹកនាំក្រសួងរួមទាំងសមត្ថកិច្ចជំនាញកំពុងបន្តជំរុញការចុះត្រួតពិនិត្យនិងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព រួមទាំងការទប់ស្កាត់ការលួចចិញ្ចឹមត្រីរ៉ស់និងត្រីឆ្តោផងដែរ។

### ៥.៦ ការប្រមូលថវិកា

- ចំណូលពីវិស័យជលផល មកទល់ពេលនេះសរុបបានចំនួន៣.០៨៤.៦៦០.៩៧៥រៀល ស្មើ៨៦,៧៩% នៃផែនការ៣.៥៥៤.៧៨១.២៥០រៀល (សម្រាប់រយៈពេល១០ខែដើមឆ្នាំ) ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន១.៨៣៥.០៣៤.២៥៧រៀល។ ដោយឡែក ក្នុងខែតុលា ឆ្នាំ២០១៥ អនុវត្តបានចំនួន២៦៨.០៦៩.២០០រៀល។

## ៦ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ចូលរួមកម្មវិធីមិត្តភាពរបស់មជ្ឈមណ្ឌលកសិកម្មអន្តរជាតិកូរ៉េសម្រាប់មន្ត្រីជាន់ខ្ពស់ប្រចាំឆ្នាំ២០១៥ នៅទីក្រុង Jeonju នៃសាធារណរដ្ឋកូរ៉េ

- ជួបពិភាក្សាជាមួយ Dr. Genn Denning, Dr. Gene Hettel និង Dr. Dule Zhao ក្នុងការផ្ដល់បទសម្ភាសន៍ និងថតខ្សែវីដេអូស្ដីពីសកម្មភាពការងារប្រចាំថ្ងៃ និងសមិទ្ធផលនានា

- បណ្ដុះបណ្ដាលកសិករស្ដីពីការគ្រប់គ្រងសារធាតុចិញ្ចឹមលើដំណាំដំឡូងមី នៅខេត្តបាត់ដំបង ដែលមានអ្នកចូលរួមចំនួន៣៤នាក់

- បណ្ដុះបណ្ដាលសហគមន៍កសិករស្ដីពីផលិតកម្មគ្រាប់ពូជ និងបច្ចេកទេសក្រោយពេលប្រមូលផល នៅស្ថានីយកាស្លាង ខេត្តស្វាយរៀង និងស្ថានីយពោធិ៍លាស់ ខេត្តព្រៃវែង ដែលមានអ្នកចូលរួមសរុបចំនួន៦៤នាក់។

## ៧ ផ្នែករដ្ឋបាល

- ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា ក្នុងខែចំនួន៣១៧ច្បាប់ (សរុបរយៈពេល១០ខែចំនួន៤.៤៥៧ច្បាប់) ទទួលពីអង្គភាពក្រោមឱវាទ ក្នុងខែចំនួន២៨៩ច្បាប់ (សរុបរយៈពេល១០ខែចំនួន៣.៣៩៥ច្បាប់) និងទទួលពីរាជធានីខេត្ត ក្នុងខែចំនួន៦០ច្បាប់ (សរុបរយៈពេល១០ខែចំនួន១.២០៩ច្បាប់) និងចាត់ចែងបន្តតាមចរន្តរដ្ឋបាល

- បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត ក្នុងខែចំនួន៥៨៦ច្បាប់ (សរុបរយៈពេល១០ខែចំនួន៧.១៥៩ច្បាប់) ប្រកាស សេចក្តីសម្រេច និងសារាចរ ក្នុងខែចំនួន២០ច្បាប់ (សរុបរយៈពេល១០ខែចំនួន២៧៥ច្បាប់) ចម្លងចែកទៅអង្គភាពក្រោមឱវាទ ក្នុងខែចំនួន៤៥ច្បាប់ (សរុបរយៈពេល១០ខែចំនួន៥៥៧ច្បាប់) និងផ្ដល់ទិដ្ឋាការបេសកកម្មចំនួន៥៥ច្បាប់ សរុបមនុស្ស៩៩នាក់

- ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិ។ល។

## ៨ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស និងទស្សនកិច្ចសិក្សាក្រៅប្រទេស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦.៦៤០នាក់ នារីចំនួន១.៣៥១នាក់ ស្មើនឹង២០% រួមមាន៖
  - + អង្គភាពថ្នាក់កណ្ដាលចំនួន៤.០៥២នាក់ ក្នុងនោះនារីចំនួន៧៧៩នាក់ ស្មើនឹង១៩%
  - + អង្គភាពថ្នាក់រាជធានី ខេត្តចំនួន២.៥៨៨នាក់ ក្នុងនោះនារីចំនួន៥៧២នាក់ ស្មើនឹង២២%

- ប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌចំនួន០២នាក់ ក្នុងនោះបោះបង់ចោលការងារចំនួន០២នាក់ សុំលាឈប់ពីការងារចំនួន០២នាក់ និងមរណភាពចំនួន០២នាក់

- ចេញច្បាប់ឈប់សម្រាកប្រចាំឆ្នាំចំនួន១៣នាក់ ច្បាប់ព្យាបាលជំងឺចំនួន០១នាក់ និងច្បាប់សម្រាកមាតុភាពចំនួន០២នាក់

- ប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន០១នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន០៥នាក់

- ប្រកាសព្យួរការងារមន្ត្រីរាជការចំនួន១៧នាក់ និងចូលបម្រើការងារវិញចំនួន១៩នាក់

- បញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទក្រសួងទៅចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន២៨នាក់ និងក្នុងប្រទេសចំនួន០៥នាក់

- ពិនិត្យនិងកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្តាល បញ្ចូលក្នុងតារាងបៀវត្សថ្មីតាមប្រព័ន្ធព័ត៌មានវិទ្យា។

## ៩ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- ចូលរួមពិភាក្សាលើសេចក្តីព្រាងកម្មវិធីសកម្មភាពជាតិប្រយុទ្ធប្រឆាំងនឹងឱនភាពដីឆ្នាំ២០១៦-២០១៨

- ចូលរួមជួបពិភាក្សាការងារកិច្ចសហប្រតិបត្តិការមេគង្គ-ឡាងឆាង

- ចូលរួមកិច្ចប្រជុំគណៈកម្មការអនុវត្តគម្រោងសហប្រតិបត្តិការត្រីភាគីចិន-កម្ពុជា UNDP លើការបង្កើនផលិតភាពដំណាំដំឡូងមីវគ្គ២ និងProject Retreat និងពិភាក្សាលើករណីស្ថានទូតអាមេរិកស្តីពីកម្មវិធីសុវត្ថិផ្នែកសុខភាពសាកល

- ចូលរួមប្រជុំផ្សព្វផ្សាយអនុវត្តគម្រោងមជ្ឈមណ្ឌលផ្សព្វផ្សាយនិងលើកកម្ពស់វិស័យកសិកម្មចិន-កម្ពុជា

- បានចាត់បញ្ជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការក្រោមឱវាទទៅចូលរួមកិច្ចប្រជុំ សន្និសីទ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាសរុបចំនួន៨៣រូប នៅប្រទេសចំនួន១១

- រៀបចំលិខិតជូនក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីស្នើសុំលិខិតឆ្លងដែនចំនួន០៣ច្បាប់ ពន្យារទិដ្ឋាការស្នាក់នៅជូនទីប្រឹក្សាកូរ៉េចំនួន១រូប និងសុំបន្តអនុស្សារណៈនៃការយោគយល់គ្នារវាងអង្គការ AVSF

- សម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយគ្រប់ដៃគូ ទាំងអង្គការជាតិ-អន្តរជាតិ និងបណ្តាប្រទេសផ្តល់ជំនួយពាក់ព័ន្ធទាំងអស់ក្នុងវិស័យកសិកម្ម។

## ១០ ការអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១០.១ សាលាជាតិកសិកម្មព្រែកលៀប

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៤-២០១៥ សរុបចំនួន១.២២៣នាក់ (ស្រី៣៩៦នាក់) ក្នុងនោះនិស្សិតថ្នាក់បរិញ្ញាចំនួន១.០១៥នាក់(ស្រី៣៤៦នាក់) និងនិស្សិតថ្នាក់បរិញ្ញារងចំនួន២០៨នាក់(ស្រី៤៦នាក់)។

និស្សិតសរុបមានការប្រែប្រួលថយចុះបន្តិចដោយសារនិស្សិតបានបញ្ចប់ការសិក្សាមានចំនួនច្រើនជាងនិស្សិតចូលថ្មី។ សាលាជាតិកសិកម្មព្រែកលៀបបានបើកថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន (ថ្នាក់បរិញ្ញាបត្រឆ្នាំទី១) សម្រាប់ឆ្នាំសិក្សា២០១៥-២០១៦។ រៀបចំជ្រើសរើសនិស្សិតថ្នាក់វិទ្យាសាស្ត្រមូលដ្ឋាននិងបរិស្ថាន(ថ្នាក់បរិញ្ញាបត្ររង)។ បន្តចុះដាំបង្គោលព្រំដីនៅស្រុកថ្ពង ខេត្តកំពង់ស្ពឺ ដែលទទួលរងការទន្ទ្រានពីប្រជាពលរដ្ឋនិងរាំងសកម្មភាពរំលោភយករបស់ប្រជាពលរដ្ឋ រៀបចំពិសោធន៍ដំណាំស្រូវជប៉ុន (Japonica seeds) ដឹកនាំនិស្សិតពិសោធន៍ដាំបន្លែក្នុងបរិវេណសាលា ចុះជួយសហគមន៍ជំរុញការដាំកូនឈើនៅឃុំពាម ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។ សហការរៀបចំការត្រៀមទទួលយកមន្ទីរពិសោធន៍ដែលជាជំនួយរបស់ប្រទេសចិន និងសាងសង់រោងគោមួយខ្នងនៅក្នុងបរិវេណសាលាជាតិកសិកម្មព្រែកលៀប។

### ១០.២ សាលាជាតិកសិកម្មកំពង់ចាម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៤-២០១៥ សរុបមានចំនួន១.២១៨នាក់(ស្រី៤៥៨នាក់) រួមមានៈ

- និស្សិតអាហារូបករណ៍សរុប៨៤៨នាក់ (ស្រី៣៤១នាក់) ក្នុងនោះថ្នាក់បរិញ្ញាវិទ្យាសាស្ត្រកសិកម្ម៦៩០នាក់ (ស្រី២៤១នាក់) និងថ្នាក់បរិញ្ញារងបច្ចេកទេសកសិកម្ម១៥៨នាក់(ស្រី១០០នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- និស្សិតសិក្សាបង់ថ្លៃ២២៨នាក់ (ស្រី៦៧នាក់) ថ្នាក់បរិញ្ញាចំនួន២១៧នាក់(ស្រី៦៦នាក់) និងថ្នាក់បរិញ្ញារងចំនួន១១នាក់ (ស្រី១នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ។

### ១០.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

និស្សិតកំពុងសិក្សាមានចំនួនសរុប៩.៩៧៧នាក់(ស្ត្រី១.៤០០នាក់) ចែកចេញជា១០មហាវិទ្យាល័យ គឺមហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញារង ថ្នាក់បរិញ្ញាវិទ្យាសាស្ត្រ និងសាលាក្រោយឧត្តមដើម្បីបណ្តុះបណ្តាលលើកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។ សាកលវិទ្យាល័យចាប់ផ្តើមបវេសនកាលឆ្នាំសិក្សាថ្មីឆ្នាំ២០១៥-២០១៦ ហើយទទួលសិស្សថ្នាក់ទី១២ ទើបប្រឡង សញ្ញាបត្រទុតិយភូមិរួចថ្មីៗចំនួន១៥០នាក់មកធ្វើទស្សនកិច្ចសិក្សាស្វែងយល់អំពីការសិក្សានៅក្នុងសាកលវិទ្យាល័យភូមិន្ទកសិកម្មដែលរៀបចំដោយ CJCC។ ប្រារព្ធពិធីសំណេះសំណាលជូនដំណើរដល់និស្សិតឆ្នាំទី៣ចំនួន១០២នាក់ ដែលត្រូវចេញទៅធ្វើកម្មសិក្សារយៈពេល១១ខែ នៅប្រទេសអ៊ីស្រាអ៊ែល។ សហការជាមួយសាកលវិទ្យាល័យ រដ្ឋមីស៊ីហ្គែន នៃសហរដ្ឋអាមេរិក ក្នុងការបើកវគ្គបណ្តុះបណ្តាលស្តីពីការវាយតម្លៃគម្រោងកម្ម-វិធីជូនដល់មន្ត្រីរាជការនិងបុគ្គលិកអង្គភាពពាក់ព័ន្ធ និងសហការជាមួយស្ថានទូតអង់គ្លេស ដើម្បីផ្សព្វផ្សាយអាហា-រូបករណ៍ទៅសិក្សាថ្នាក់បរិញ្ញាជាន់ខ្ពស់ និងបណ្ឌិតនៅប្រទេសអង់គ្លេស ជូនដល់និស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្ម។ សាកលវិទ្យាល័យបានចុះហត្ថលេខាលើអនុស្សរណៈអំពីកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យ Shinji ប្រទេសជប៉ុន និងប្រជុំជាមួយគណៈប្រតិភូចលនាភូមិថ្មីរបស់កូរ៉េ ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការក្នុងការអនុវត្តកម្មវិធីចលនាភូមិថ្មីនៅក្នុងប្រទេសកម្ពុជា។

គ្រឹះស្ថានឧត្តមសិក្សាកសិកម្មទាំង៣ខាងលើ តែងតែបញ្ជូននិស្សិតឱ្យចុះធ្វើកម្មសិក្សានៅតាមអង្គភាពជំនាញនៅទីវាល និងតាមបណ្តាក្រុមហ៊ុនមួយចំនួនដូចខែមុនៗដែរដើម្បីផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងក៏ដូចជាការបង្ហាត់ឱ្យចេះកែច្នៃកសិផលមួយចំនួនសម្រាប់ការធ្វើកសិពាណិជ្ជកម្ម រួមទាំងការពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូឱ្យកាន់តែទូលំទូលាយ។

### ១០.៤ សកម្មភាពផ្សេងៗ

ក. បានចូលរួមសហការជាមួយក្រសួង ស្ថាប័ន អង្គការជាតិ និងដៃគូពាក់ព័ន្ធក្នុងសកម្មភាពយេនឌ័រនិងកុមារ ក៏ដូចជាការបញ្ជ្រាបកម្មវិធីនេះទៅក្នុងគម្រោងផ្សេងៗតាមផ្នែកសំខាន់ៗក្នុងវិស័យកសិកម្ម។

ខ. ការធ្វើអធិការកិច្ច ក៏ដូចជាកិច្ចការសវនកម្មផ្ទៃក្នុងបានប្រព្រឹត្តទៅតាមផែនការឆ្នាំ២០១៥ ដែលបានគ្រោងទុក។

គ. ការចុះត្រួតពិនិត្យ ការងារផ្សព្វផ្សាយអប់រំ និងលើកកម្ពស់ការយល់ដឹងអំពីការអនុវត្តច្បាប់ក្នុងការគ្រប់គ្រងសម្ភារកសិកម្ម ក៏បានដំណើរការទៅតាមផែនការដែលបានដាក់ចុះក្នុងឆ្នាំ២០១៥ ជាអាទិ៍: (១)-បានចុះធ្វើសិក្ខាសាលាផ្សព្វផ្សាយអំពីការលើកកម្ពស់ការយល់ដឹងអំពីបទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសក្នុងការគ្រប់គ្រងការធ្វើអាជីវកម្មសម្ភារកសិកម្មនៅខេត្តព្រះវិហារ សៀមរាប និងកំពង់ធំ ដែលមានសិក្ខាកាមចូលរួមសរុប១៧៣នាក់។ (២)-រៀបចំវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ និងធ្វើជាគ្រូឧទ្ទេសនាមដោយមានសិក្ខាកាមចូលរួម៤៥នាក់។ (៣)-បែងចែកឯកសារច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្មចំនួន១៥០ក្បាល និងឯកសារសម្រាប់មន្ត្រីអធិការកិច្ចស្តីពីថ្នាំកសិកម្មហាមឃាត់និងថ្នាំកសិកម្មអនុញ្ញាតឱ្យប្រើប្រាស់ចំនួន១៨០ក្បាល។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

នៅចុងរដូវវស្សាឆ្នាំ២០១៥នេះ អាកាសធាតុមានការប្រែប្រួល និងមានភ្លៀងធ្លាក់តិចតួចនៅដើមរដូវដោយតំបន់ ហើយចាប់ពីពាក់កណ្តាលខែកក្កដារហូតដល់ចុងខែសីហា គ្រោះរាំងស្ងួតបានកើតមាននៅតាមបណ្តាខេត្តមួយចំនួនដែលធ្វើឱ្យការងារដាំដុះដំណាំស្រូវមានការយឺតយ៉ាវជាងឆ្នាំមុន និងធ្វើឱ្យខូចខាតសំណាបចំនួន៦៤ហ.ត និងស្រូវសន្ទូងនិងពង្រោះចំនួន១៤.០៤៤ហ.ត។ ទោះជាយ៉ាងណាក៏ដោយ គិតមកត្រឹមថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥នេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៥ អនុវត្តបានចំនួន២.៥៥៥.១១៨ហ.ត ស្មើនឹង៩៩.៥៣% នៃផែនការ២.៥៦៧.១៣០ហ.ត តិចជាងឆ្នាំមុនចំនួន២.៨៥៥ហ.ត។ ក្នុងគោលបំណងដើម្បីបង្កើនទិន្នផលស្រូវឱ្យបានច្រើនជាអតិបរមា និងកាត់បន្ថយនូវការបាត់បង់ស្រូវអង្ករ ទាំងបរិមាណ និងគុណភាពនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើការណែនាំដល់គ្រប់អង្គភាពក្រោមឱវាទដែលពាក់ព័ន្ធ និងមន្ទីរកសិកម្មរាជធានី-ខេត្តទូទាំងប្រទេស ឲ្យយកចិត្តទុកដាក់ខ្ពស់បំផុត ដើម្បីធ្វើការណែនាំដល់ប្រជាកសិករ ផលិតករ និងអ្នកពាក់ព័ន្ធទាំងអស់ឱ្យអនុវត្តនូវវិធានការចាំបាច់មួយចំនួនដូចការរក្សាទឹកទុក ការថែទាំ និងប្រមូលផលស្រូវរដូវវស្សាឆ្នាំ២០១៥ ខាងក្រោម៖

• ការមើលថែទាំអាងស្តុកទឹក ទំនប់ប្រឡាយនិងប្រព័ន្ធភ្លឺស្រែឱ្យបានគត់មត់ល្អ ដើម្បីរក្សាទឹកទុកក្នុងអាងនិងក្នុងស្រែឱ្យបានគ្រប់គ្រាន់ និងសន្សំសំចៃខ្ពស់ចៀសវាងការខ្វះទឹកនៅចុងរដូវនៅពេលស្រូវមិនទាន់ទុំល្អ ។

• ការត្រៀមលក្ខណៈបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៦ ត្រូវសិក្សាវាយតម្លៃនិងរៀបចំផែនការផលិតកម្មឱ្យបានច្បាស់លាស់ ដោយពិនិត្យទៅលើស្ថានភាពប្រភពទឹកនិងបរិមាណទឹកដែលមាននៅតាមតំបន់នីមួយៗព្រមទាំងរក្សាទឹកទុកសម្រាប់ការបង្កបង្កើនផលស្រូវរដូវប្រាំង ដើម្បីចៀសវាងការខ្វះទឹកស្រោចស្រពនៅចុងរដូវបណ្តាលឱ្យថយចុះទិន្នផលឬបាត់បង់ទិន្នផលស្រូវទាំងស្រុង។

ចំពោះការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ និងជលផល គឺស្ថិតនៅតែជាប្រធានបទអាទិភាព ដែលអង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗជាធរមានយ៉ាងយកចិត្តទុកដាក់ ដោយជំរុញការចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសព្រៃឈើនិងជលផលតាមគ្រប់រូបភាពពិតមែនតែនៅជួបប្រទះបញ្ហាប្រឈមខ្លះៗក៏ដោយរហូតដល់មន្ត្រីជំនាញមួយចំនួនទទួលរងនូវការគំរាមកំហែង និងគ្រោះថ្នាក់ដល់អាយុជីវិតក៏មាន។ លើសពីនេះទៀត ផ្នែកសេវាកម្ម ដំណើរការនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់តាមផ្នែកសំខាន់ផ្សេងៗ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មជី-ថ្នាំកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការឆ្នាំ ២០១៥នេះ។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ :

- តាមដាននិងអន្តរាគមន៍ចំពោះការផ្ទុះរាលដាល និងការបំផ្លាញដោយសត្វល្អិតជាយថាហេតុចំពោះដំណាំកសិកម្មផ្សេងៗនិងជំរុញការងារបង្កបង្កើនផលរដូវវស្សានេះឱ្យបានសម្រេចតាមផែនការ

- តាមដានចលនានាំចេញស្រូវនិងថ្លៃស្រូវ ជាពិសេសតាមច្រកព្រំដែននានា

- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ឬប្រើប្រាស់ពូជស្រូវសមស្របជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាព ដើម្បីស្តារការដាំដុះឡើងវិញឱ្យបានទាន់ពេលវេលានៅតំបន់ដែលទទួលរងការខូចខាតដោយគ្រោះរាំងស្ងួត ព្រមទាំងត្រៀមបម្រុងគ្រាប់ពូជស្រូវសម្រាប់ផ្តល់ជូនកសិករក្រីក្រដែលពុំមានលទ្ធភាពទិញគ្រាប់ពូជជាពិសេសចំពោះខេត្តដែលមានអត្រាស្បៀង (អង្ករ) ដោយជំរុញកសិករឱ្យធ្វើការដាំដុះស្រូវស្រាលឬស្រូវកណ្តាលដើម្បីកាត់បន្ថយផលប៉ះពាល់បង្កដោយគ្រោះរាំងស្ងួត គ្រោះខ្វះទឹកដែលអាចកើតឡើងជាយថាហេតុនៅចុងរដូវ និងដាំដំណាំរួមផ្សំ ដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ និងកាត់បន្ថយការចំណាយថ្លៃដើមឱ្យបានច្រើនដើម្បីផ្តល់កម្រៃបន្ថែមជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ

- ពិនិត្យ ពង្រឹងឡើងវិញ ដើម្បីត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិពាណិជ្ជកម្ម

- អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្មរាជធានី-ខេត្ត ត្រូវសហការឱ្យបានល្អជាមួយគ្រប់ស្ថាប័នពាក់ព័ន្ធនិងអាជ្ញាធរមូលដ្ឋាន ព្រមទាំងកសិករ ម្ចាស់ម៉ាស៊ីនកិនស្រូវ និងអ្នកទិញ-លក់ស្រូវអង្ករមានវិធានការជាបន្ទាន់ដោយប្រើប្រាស់កម្លាំងសរុប ដើម្បីជំរុញការថែទាំស្រូវវស្សា ព្រមទាំងទប់ស្កាត់ការបាត់បង់ទាំងបរិមាណនិងគុណភាពស្រូវអង្ករនៅពេលប្រមូលផល សំដៅរួមចំណែកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករឱ្យទទួលបានជោគជ័យនិងការត្រៀមលក្ខណៈដាំដុះស្រូវប្រាំងឱ្យទទួលបានលទ្ធផលល្អ ក្នុងន័យធានាបាននូវសន្តិសុខស្បៀងនិង ការកាត់បន្ថយភាពក្រីក្រ

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍កូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

- បន្តស្រាវជ្រាវការដាំដុះសាកល្បងកូនកៅស៊ូប្រភេទ "Invitro" និងបន្តផ្សព្វផ្សាយអំពីបច្ចេកទេសដ៏មានសារសំខាន់នេះក្នុងក្របខ័ណ្ឌនៃគម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូនៅកម្ពុជា។

**២ ផ្នែកផលិតកម្មនិងបសុព្យាបាល :**

- បន្តចាត់វិធានការដោយសហការជាមួយស្ថាប័ននិងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺជ្រូកគ្រុនចៀកខៀវ និងចាត់ក្រុមការងារចុះអប់រំណែនាំនិងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្មរាជធានី ខេត្ត ស្រុក ដើម្បីត្រៀមនិងចាត់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង។ បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀតព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត និងបង្កើនការលើកកម្ពស់ការចិញ្ចឹមសត្វគ្រប់ប្រភេទនៅក្នុងស្រុកឱ្យបានទូលំទូលាយ

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្វតាមលក្ខណៈសិប្បនិម្មិតនិងដំណាំចំណីសត្វនៅទូទាំងប្រទេស

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកគ្រុនចៀកខៀវ ប៉េស្ត និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

- ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត ពិសេសការពង្រឹងការអនុវត្តវិធានបច្ចេកទេសនៅតាមបណ្តាសត្តឃាតដ្ឋានឱ្យបានសមស្របតាមនីតិវិធី

- ជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងបសុព្យាបាល។

**៣ ផ្នែកព្រៃឈើ :**

- បន្តជំរុញដាក់ឱ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការ និងតាមការពិន័យអន្តរការណ៍

- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីផ្នែកព្រៃឈើ តាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឱ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តការដាំកូនឈើ និងដាំឈើឱ្យបានទូលំទូលាយតាមផែនការដែលបានគ្រោងទុក

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ សត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរេចរឹលឱ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២។

**៤ ផ្នែកជលផល :**

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល

- ពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងតំបន់នេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តស្រាវជ្រាវដកហូត និងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

- រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឱ្យបានគ្រប់ឃុំ

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៥ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្គា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ។

**៥ ផ្នែកពាក់ព័ន្ធផ្សេងៗ** :

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមបណ្តាខេត្ត រាជធានី។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម

- ពង្រឹងការងារបញ្ជីការគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មខេត្ត រាជធានី ក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញ ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលបង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឱ្យបានទូលំទូលាយ។ ទន្ទឹមនឹងនេះ ក៏បានគិតគូរអំពីការបញ្ចូលការងារយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់តាមផ្នែកនីមួយៗផងដែរ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទតាមផែនការឆ្នាំដែលបានគ្រោងទុក និងតាមសកម្មភាពជាក់ស្តែង

- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ឱ្យបានសមស្របទៅតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលមន្ត្រីរាជការទាំងក្នុងនិងក្រៅប្រទេស

- ជំរុញការយកចិត្តទុកដាក់រៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្ត អត្ថបទក្រោមច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ស្តង់ដារ គោលការណ៍ និងហេដ្ឋារចនាសម្ព័ន្ធនៅតាមអង្គភាពក្រោមឱវាទ ដើម្បីអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាពីកសិកម្មបែបវិបុលកម្ម មានផលិតភាពទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាកសិកម្មបែបប្រពលវប្បកម្ម មានផលិតភាពខ្ពស់និងផលិតសម្រាប់ធ្វើពាណិជ្ជកម្មក្នុងការត្រៀមលក្ខណៈសមាហរណកម្មចូលរួមក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននៅចុងឆ្នាំ២០១៥ និងនាពេលអនាគត។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**